PTI0087

# សម្ភាសជាមួយឈ្មោះ ជ័យ ខន ភេទ ប្រុស អាយុ ៥៩ឆ្នាំ

មុខងារខ្មែរក្រហមៈ កងទ័ព

មុខងារបច្ចុប្បន្នៈ ធ្វើស្រែ

មានស្រុកកំណើតនៅៈ ភូមិព្រៃវែង ឃុំក្រាំងនីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

សព្វថ្ងៃរស់នៅភូមិចំការជ្រៃខាងត្បូង ឃុំអន្ទង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១១

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០០:៤៨:០៩

## ទំព័រ២៣

ប៊ុនថន : អញ្ចឹងខ្ញុំអនុញ្ញាតសួរឈ្មោះលោកពូៗឈ្មោះអីដែរលោកពូ?

ខន : បាទ!ខ្ញុំឈ្មោះ ជ័យ ខនៗ

ប៊ុនថន : ជ័យ ខន អាយុប៉ុន្មានហើយលោកពូ?

ខន : ខ្ញុំអាយុ ៥៩ឆ្នាំៗ

ប៊ុនថន : លោកពូមានស្រុកកំណើតនៅភូមិឃុំអីដែរលោកពូ?

ខន : បាទ!ស្រុកកំណើតខ្ញុំនៅស្រុកភ្នំស្រួច ឃុំក្រាំងនីវ៉ាយ ភូមិព្រៃវែង ខេត្តកំពង់ស្ពឺៗ

ប៊ុនថន : បាទ!អញ្ចឹងសព្វថ្ងៃពូរស់នៅណាពូ?

ខន : បាទ!សព្វថ្ងៃនេះខ្ញុំរស់នៅភូមិចំការជ្រៃខាងត្បូង ឃុំអន្ទង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ៗ

ប៊ុនថន : បាទ!ពូមានបងប្អូនប៉ុន្មាននាក់ពូ?

ខន : ខ្ញុំមានបងប្អូនគិតទៅវា ១២នាក់ ហើយសព្វថ្ងៃរស់នៅ៤នាក់ ៥នាក់ទាំងខ្ញុំ ស្រី៣ ប្រុស២ ៥នាក់ៗ

ប៊ុនថន : បាទ!ចុះ៦នាក់ទៀត?

ខន : បាទ?

ប៊ុនថន : ចុះនៅសល់៦នាក់ទៀត?

ខន : នៅសល់៥នាក់ ៣,៤,៥ នៅសល់៥នាក់ក្រៅពីហ្នឹងស្លាប់ៗ

ប៊ុនថន : ស្លាប់ជំនាន់ណាវិញលោកពូ?

ខន : ស្លាប់ជំនាន់សង្គ្រាម៣នាក់ អុស៊់!២នាក់ ។

ប៊ុនថន : សង្គ្រាម៥ឆ្នាំហ្នឹងលោកពូ?

ខន : បាទ!សង្គ្រាម៥ឆ្នាំហ្នឹង២នាក់ ហើយស្លាប់សម័យយើងសន្តិភាពហើយហ្នឹង ដោយជំងឺម្នាក់ ។

ប៊ុនថន : បាទ!អញ្ចឹងនៅសល់តែ៥នាក់ទេ?

ខន : បាទ!នៅសល់តែ៥នាក់ ។

ប៊ុនថន : គាត់រស់នៅណាលោកពូ?

ខន : បងប្អូនខ្ញុំ ប្អូនប្រុសម្នាក់រស់នៅសំឡូត ប្អូនស្រីៗនៅឯស្រុក នៅភ្នំស្រួច ខេត្ត កំពង់ស្ពឺ ។

ប៊ុនថន : ចុះឪពុកម្តាយនៅរស់ទេលោកពូ?

ខន : ឪពុកម្តាយស្លាប់អស់ហើយ ស្លាប់ទាំងអស់ ។

ប៊ុនថន : គាត់ស្លាប់ជំនាន់ណាដែរលោកពូ?

ខន : ម្តាយខ្ញុំស្លាប់ពីឆ្នាំ១៩០០ កិច្ចព្រមព្រៀងប៉ារីស៩០?

ប៊ុនថន : ៩១?

ខន : គាត់ស្លាប់៩២ ។

ប៊ុនថន : បាទ!បានមួយឆ្នាំ?

ខន : បាទ!ឪពុកខ្ញុំទើបតែស្លាប់ឆ្នាំ២០០៩ទេ ឥឡូវ២០១០ហើយទើមស្លាប់បានមួយឆ្នាំ ។

ប៊ុនថន : អញ្ចឹងពូ!ពីតូចលោកពូបានរៀនដល់ថ្នាក់ណាដែរ?

ខន : ខ្ញុំពីតូចខ្ញុំរៀនថ្នាក់ទី១២ ពីសង្គមចាស់ ។

ប៊ុនថន : ថ្នាក់ទី១២ ស្មើនឹងថ្នាក់ទី១ឥឡូវពូ?

ខន : បាទៗ!ពីដើមថ្នាក់ទី១២ហ្នឹងវាអត់ជាងគេហើយ មើលបាន សរសេរបាន ។

ប៊ុនថន : ហើយក្រោយពីឈប់រៀនហ្នឹង ពូធ្វើអីទៀតពូ?

ខន : ក្រោយពីឈប់រៀនឆ្នាំ៧០ខ្ញុំទៅ ពេលដែលរដ្ឋប្រហារខ្ញុំទៅបួសជាសង្ឃ បួសបានមួយឆ្នាំហ្នឹងខ្ញុំសឹកម៉ោវិញៗម៉ោវិញ ខ្ញុំចូលកងទ័ព ខាងកងទ័ពហ្នឹងគឺឈ្លបជំនាន់ខ្មែរក្រហម ហ្នឹងចូលឈ្លបនៅឈ្លបឃុំបានចំនួនមួយឆ្នាំៗ ឆ្នាំ៧០-៧១ គេបញ្ជូនទៅស្រុក ។

ប៊ុនថន : ទៅខាងទ័ពស្រុកវិញ?

ខន : បាទ!ទ័ពស្រុកហើយ ចូលទ័ពតំបន់បណ្តោយ ។

ប៊ុនថន : បាទ!

ខន : បាទ!តំបន់ៗកំពង់ស្ពឺខាងជើង ។

ប៊ុនថន : តំបន់ប៉ុន្មានលោកពូ?

ខន : តំបន់ហ្នឹងគេហៅតំបន់៣២ ។

ប៊ុនថន : តំបន់៣២?

ខន : បាទៗ!កាលហ្នឹងគេហៅតំបន់៣២ កំពង់ស្ពឺខាងជើង ៣២កំពង់ស្ពឺខាងត្បូង ៣៣បន្តិច ខ្ញុំនៅខាងជើង ។

ប៊ុនថន : បាទ!មានស្រុកអីខ្លះពូមាននៅចាំទេតំបន់៣២?

ខន : តំបន់៣២ហ្នឹងវាមានស្រុកភ្នំស្រួច អាហ្នឹងដែលខ្ញុំរស់នៅ ។

ប៊ុនថន : បាទៗ!

ខន : ស្រុកភ្នំស្រួច ស្រុកស្តង់ ស្រុកខត្តុង ខ្ញុំចាំបាន៣ហ្នឹង ។

ប៊ុនថន : តែ៣ទេ?

ខន : បាទៗ!ព្រោះខ្ញុំនៅទ័ពកាលហ្នឹងវាឆ្នាំ៧០ហ្នឹងវាមិនសូវបានដើរអី ទៅណាណីទេ ដូច្នេះ ខ្ញុំចូលទៅក្នុងទ័ពហ្នឹង ទ័ពតំបន់ហ្នឹងគឺថាកំពង់ស្ពឺខាងជើងហ្នឹងគឺតំបន់៣២ អញ្ចឹងក្នុងទ័ព ហ្នឹង ខ្ញុំមិនដឹងថាគោលនយោបាយរបស់ខ្មែរក្រហមកាលហ្នឹងគឺថាវ៉ៃ លន់ ណុល ដើម្បីរំដោះជាតិ ។

ប៊ុនថន : បាទៗ!

ខន : អញ្ចឹងការប្រយុទ្ធរបស់ខ្ញុំគឺមានការស្រេវស្រើបណាស់ ចាប់ពី៧០ម៉ោ ការប្រយុទ្ធ អត់ដែលបានម៉ោផ្ទះទេៗ គឺប្រយុទ្ធគ្នារហូតទាល់ខ្ញុំឡើងសម្ព័ន្ធ គេហៅថាសម្ព័ន្ធយុវជន បាទ!ឈានមុខណាស់សម្ព័ន្ធយុវជនកាលហ្នឹង ។

ប៊ុនថន : បាទ!ពូបានចូលដែរ?

ខន : បាទ!បានចូលក្នុងសម្ព័ន្ធយុវជនគេហ្នឹងគឺថា គេហៅថាសម្ព័ន្ធយុវកង ។

ប៊ុនថន : បាទ!សម្ពន្ធ័យុវកង?

ខន : បាទ!សម្ពន្ធ័យុវកងហ្នឹងគឺថា ថ្នាក់ខ្ញុំឡើងដល់មេក្រុម ដល់មេក្រុមហើយឡើងដល់អនុ សេនាតូច ការប្រយុទ្ធស្រេវស្រាវនៅខាងមុខ គឺមិនដែលបានម៉ោក្រោយគេទេ ។

ប៊ុនថន : អញ្ចឹងពូបានឡើងដល់អនុសេនាតូចដែរ?

ខន : បាទ!ឡើងដល់អនុសេនាតូច ខ្ញុំបានឡើងដល់វរៈសេនាធំទៀត អនុសេនាតូចឆ្នាំ៧០-៧១ ៧៣ខ្ញុំឡើងបក្សជន ។

ប៊ុនថន : អ៊ូ!ពូបានឡើងដល់បក្សជណដែរ?

ខន : បាទ!បានឡើងដល់បក្សជន ខ្ញុំនិយាយត្រង់ អត់មានលាក់លៀមទេ ។

ប៊ុនថន : បាទ!

ខន : បានឡើងបក្សជនហ្នឹង បានឡើងអនុសេនាធំ ប្រយុទ្ធជាមួយទាហានលន់ ណុល គេហៅខ្មែរអាមេរិចកាំងនោះណា៎ ។

ប៊ុនថន : បាទ!

ខន : ការតស៊ូកាលហ្នឹងគឺវាខ្លាំងខ្លាណាស់ ឆ្នាំ៧៣មាន (b52) ហើយការប្រជុំកាលហ្នឹង ការប្រជុំក្រោយម្តងៗគេហៅមេវរៈសេនាធំ មេកងពលគេហៅម៉ោ កាលហ្នឹងតំបន់មានតែវរៈសេនាធំទេ អត់មានកងពលទេ ។

ប៊ុនថន : អត់ទាន់មានកងពលទេ?

ខន : បាទ!អត់មានទេ ក្នុងតំបន់អត់មានកងពលដូចភូមិភាគ ដូចភូមិភាគពិសេសអីទៀតទេ ។

ប៊ុនថន : បាទ!

ខន : ក្នុងតំបន់មួយៗមានតែវរៈសេនាធំទេ វរៈធំមានតែ២វរៈសេនាតូច ឬ៣វរៈសេនាតូចតែប៉ុណ្ណឹងទេ ។ អញ្ចឹងខ្ញុំនិយាយវែងបន្តិចហើយ?

ប៊ុនថន : បាទៗ!អត់អីទេលោកពូអាចរៀបរាប់បានច្រើន ។

ខន : ដល់អញ្ចឹងទៅខ្ញុំ៧៣ ៧៣ខ្ញុំឡើងដល់អនុសេនាធំ មេបញ្ជាការអនុសេនាធំ ការប្រយុទ្ធតឹងតែងណាស់អូនកាលនោះ គ្រាប់បែក(B52) អាមេរិចកាំងគឺថាម៉ោ ទម្លាក់ខ្មែរត្រៀមវាប្រើអស់ហើយ ឯចំណែកខ្ញុំវិញគឺថាសង្គ្រាមប្រើដោយសង្គ្រាមប្រជាជន អាវុធហ្នឹងគឺប្រើសន្សំសំចៃបំផុតណាស់ ។

ប៊ុនថន : បាទ!តិចតួច?

ខន : បាទ!តិចតួច ហើយគ្រាប់រំសេវអីគឺអត់ឲ្យខ្ជះខ្ជាយទេ គឺថាគ្រាប់មានប៉ុន្មាន គឺវៃយកពីទាហានលន់ ណុល យកទៅវៃវាវិញ បាទ!វៃទីតាំងមួយៗបានគឺយើងទៅយក ហើយយកម៉ោវិញ ការឧបត្ថមខាងក្រោយតិចណាស់ បាយចំណី បាយទឹកក្តីគឺថាមានតែបាយខ្ចប់ទេមានការលំបាក ហើយចំពោះខ្ញុំបានឡើងម៉ោធ្វើមេកង គឺអត់សូវម៉ោក្រោយគេទេ នៅតែមុខជាប់ស្តាប់សភាពការណ៍វៃសមរភូមិមុខយកការដើម្បីដឹកនាំកម្លាំងវៃនៅខាងមុខ ហ្នឹង៧៣ហើយ ។

ប៊ុនថន : បាទៗ!៧៣ពូឡើងដល់វរៈសេនាធំ?

ខន ៖ អនុសេនាធំ ។

ប៊ុនថន ៖ អនុសេនាធំលេខប៉ុន្មានពូ កាលហ្នឹងមានបែងចែកទេ?

ខន ៖ កាលហ្នឹងនិយាយកងវរៈ ខ្ញុំចង់ភ្លេចហើយអូន បែកៗកងវរៈ១៣៧ ។

ប៊ុនថន ៖ ១៣៧?

ខន ៖ វរៈសេនាតូច ។

ប៊ុនថន ៖ បាទ!

ខន ៖ អនុសេនាធំហ្នឹងដូច៧៧ឬ៧៨ទេ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងមុខព្រួញពូវើកន្លែងណាខ្លះ?

ខន ៖ មុខព្រួញខ្ញុំនៅកំពង់ស្ពឺហ្នឹងគឺខ្ញុំវើចាប់ពីថ្នល់ទទឹងភ្នំស្រួច ថ្នល់ទទឹងគេហៅព្រៃរមេលនេះ ភ្នំដាច់នេះ ។

ប៊ុនថន ៖ បាទ!

ខន ៖ ភ្នំដាច់ទៅទល់នឹងអន្លុងឈ្នួល ។

ប៊ុនថន ៖ អន្លុងឈ្នួល?

ខន ៖ បាទ!បែកចាននេះខាងលិចភ្នំពេញ មុខព្រួញហ្នឹងចល័តទៅម៉ោៗ ការពិតមិនដល់បែកចានដងទេ ស្មើថ្នល់ទទឹងខាងកើត ។

ប៊ុនថន ៖ បាទ!

ខន ៖ ថ្នល់ទទឹងអាកាត់ម៉ោតាមថ្នល់ជាតិលេខ៤អូន ។

ប៊ុនថន ៖ បាទៗ!

ខន ៖ ពីលូដាច់នេះម៉ោខាងតំបន់ចល័តជាប់ម៉ង ។

ប៊ុនថន ៖ តំបន់៣២នេះ?

ខន ៖ តំបន់៣២ ។

ប៊ុនថន ៖ កាលនោះខាងតំបន់ហ្នឹងខាងណាជាអ្នកគ្រប់គ្រងវិញពូ?

ខន ៖ តំបន់គ្រប់គ្រងគឺតំបន់ហ្នឹងជាអ្នកគ្រប់គ្រង ។

ប៊ុនថន ៖ បាទ!ពីណាវិញកាលហ្នឹង?

ខន ៖ គណៈតំបន់កាលហ្នឹងគឺ តាប៉ាវៗ តាប៉ាវពីដើមគាត់គ្រប់គ្រងតំបន់ហ្នឹង បន្ទាប់ពីតាប៉ាវហ្នឹងម៉ោឈ្មោះបង កន ឈ្មោះកន ហ្នឹងគេបន្ទាប់ពីតាប៉ាវ ហើយបើទទួលផ្ទាល់នៅក្នុងតំបន់ហ្នឹង ក្នុងកងវរៈសេនាធំហ្នឹងឈ្មោះ បងធីម ។

ប៊ុនថន : អី ធីម គាត់ឈ្មោះ?

ខន : អេសស៎!មិនដឹងអីធីមទេភ្លេចហើយ គាត់ដឹកនាំខ្លាំងណាស់ តែគាត់ពីដើមគាត់អ្នកស្នេហាជាតិអ្នករំដោះជាតិ វ៉ៃ លន់ ណុលរំដោះជាតិ វ៉ៃអាមេរិចកុំឲ្យទម្លាក់គ្រាប់ ។

ប៊ុនថន : បាទ!

ខន : បាទ!អញ្ចឹងតាំងតាំងខ្ញុំប្រយុទ្ធខ្លាំងៗណាស់ពេលហ្នឹង ។

ប៊ុនថន : បាទ!ចុះតាសែ អីគាត់នៅនេះនៅខាងតំបន់ដែរពូ?

ខន : តាសែណា?

ប៊ុនថន : តាសែ កងចាបនោះ?

ខន : អ៊ូៗ!អានោះគាត់នៅផ្សេងទេ នៅតំបន់ផ្សេងទេ ។

ប៊ុនថន : តំបន់ផ្សេងទេ?

ខន : កងផ្សេងទេ កងចាប តាសែដូចនៅខាង ខ្ញុំមិនសូវស្គាល់ទេ មិនស្រួលនៅខាងពិ សេស ភូមិភាគពិសេសហ្នឹង ។

ប៊ុនថន : នៅខាងត្បូងភ្នំពេញភូមិពិសេស?

ខន : បាទៗ!និយាយរួមភូមិភាគអីហ្នឹងគឺខ្ញុំអត់សូវស្គាល់គេទេរឿងភូមិភាគអី ហ្នឹងគឺខ្ញុំអត់សូវស្គាល់ទេអូន តំបន់វ៉ៃតែក្នុងក្របខ័ណ្ឌតែប៉ុនហ្នឹង ដូចខ្ញុំថាពីថ្នល់ទទឹងម៉ោលូកដែកលូដែកទៅថ្នល់ទទឹងម៉ាខែចល័តចុះចល័តឡើងហ្នឹង ។

ប៊ុនថន : បាទ!អញ្ចឹងខាងតំបន់ពូអត់សូវស្គាល់ទេ ស្គាល់តែខាងកងទ័ពនេះទេ?

ខន : បាទៗ!ស្គាល់តែទ័ពទេ ហើយម៉ោសម្រាកក្រោយម្ដងៗម៉ោ ម៉ោសម្រាកប្រជាជនហ្នឹងស្គាល់ប្រជាជនខ្លះម៉ាភ្លាតៗហ្នឹង ខ្លះបានម៉ាអាទិត្យអីហ្នឹងម៉ោអញ្ចឹងទៅដើរលេងផ្ទះប្រជាជនអី ប្រជាជនក៏គាត់មានការអាណិតអាសូរមានបាយមានទឹកអីរៀបចំឲ្យទ័ព ហើយទ័ពយើងក៏អត់ដែលធ្វើអីប៉ះពាល់ យើងជួយស្ទូងជួយដកគាត់ទៅ ម៉ោវិញម៉ោពីវ៉ៃវិញទៅជួយដកជួយស្ទូងគាត់ទៅ អញ្ចឹងទៅ ហើយនេះក៏ទៅវិញទៅ បាទ!តែប៉ុនហ្នឹងអូន ។

ប៊ុនថន : បាទ!ចុះអានុសេនាធំពូឈរជើងនៅណាពូ?

ខន : អនុសេនាធំខ្ញុំដែលឈរជើងបំផុតនៅលូដាច់នេះ នៅម៉ាម្ដុំភ្នំស្រួចនេះ បាទនៅព្រោះកាលហ្នឹងយើងម៉ោសម្រាកនៅក្រោយ គេហៅនៅឈើជ្រុំៗនៅខាងក្នុងឃុំៗ ឥឡូវគេហៅឃុំតាំងសំរោង ។

ប៊ុនថន ៖ តាំងសំរោង?

ខន ៖ បាទ!តាំងសំរោង កាលហ្នឹងយើងម៉ោសម្រាកក្រោយហើយ ពេលដែលយើងដកទ័ពពីមុខម៉ោយើងសម្រាកម៉ាអាទិត្យអី មេបញ្ជាគេសេដ្ឋកិច្ចអីគេនៅក្រោយ វាវែងពេកហើយអូន។

ប៊ុនថន ៖ អត់អីទេលោកពូ ពូរៀបរាប់ឲ្យបានច្រើន?

ខន ៖ បាទ!អាហ្នឹងពីប្រវត្តិខ្ញុំ ហើយផ្ទះក៏ដែលបានម៉ោទេ ចង់ម៉ោក៏អត់បានម៉ោដែរ គេអត់មានពេលអីឲ្យម៉ោទេ។

ប៊ុនថន ៖ ចេញតែពេលពូចូលកងហ្នឹងហើយ ចេញរហូតទៅ?

ខន ៖ បាទ!ដល់អញ្ចឹងចេញរហូត ផ្ទះសំប្បែងអត់ដែលបាននៅទេ ឪពុកម្ដាយនៅក្រោយសហករណ៍ សហគមន៍គេក្រោយអត់ដឹងទេ ដឹងតែពីវៃ អញ្ចឹងខ្ញុំសង្ខេបបន្តិចចុះ ដល់ក្រោយម៉ោយើងរំដោះ៧៥ ។

ប៊ុនថន ៖ បាទ!លោកពូខ្ញុំចង់សួរបន្តិចទៀត លោកពូនៅខាងទ័ពតំបន់រហូត អត់ដែលបានឡើងភាគអីនឹងគេទេ?

ខន ៖ អត់ទេ!ទៅតំបន់រហូតម៉ង់ ។

ប៊ុនថន ៖ ចុះខាងណាមេបញ្ជាការដូចថាខាងតំបន់?

ខន ៖ តំបន់ដូចខ្ញុំថាអញ្ចឹង ឃឹមហ្នឹង ។

ប៊ុនថន ៖ ឃឹម?

ខន ៖ បាទ!អីឃឹម ទេគឺគាត់មេបញ្ជានៅហ្នឹងម៉ង ។

ប៊ុនថន ៖ បាទ!ខាងភាគហ្នឹង ហើយតំបន់ខុសគ្នាយ៉ាងម៉េចលោកពូ?

ខន ៖ ខុសគ្នា គឺខាងភូមិភាគគេឲ្យភូមិភាគនិរតីអញ្ចឹង ពីនិរតីហ្នឹងមានតាម៉ុក តាកាន់អញ្ចឹង ។

ប៊ុនថន ៖ បាទ!អាហ្នឹងធំ?

ខន ៖ ភូមិភាគហ្នឹងគឺមានកងពលគេ បាទ!កងពលដូចថាម៉ាភូមិភាគហ្នឹង ភូមិភាគបញ្ចឹមអញ្ចឹងភូមិភាគបញ្ចឹម ភូមិភាគនិរតីផ្សេង ភូមិភាគបញ្ចឹមចាប់តាំងពីខាងភូមិភាគបញ្ចឹមគេគិតពីខាងដើងថ្នល់ជាតិលេខ៤រហូតតល់នឹងកំពង់ឆ្នាំង ។

ប៊ុនថន ៖ បាទៗ!

ខន : បាទ!ភូមិភាគនិរតីគេចាប់ពី អូស៎!បញ្ចឹម ទៅនឹងកោះកុង ភូមិភាគនិរតីគេចាប់ពីកំពត តាកែវ មិនទល់ណាទៀតទេ អាហ្នឹងគេចែកគ្នាថ្នល់ជាតិអញ្ចឹង ហើយក្នុងភូមិភាគវា មាន២កន្លែងពលឬក៏៣កន្លែងគេធំ អាហ្នឹងខ្ញុំគ្រាន់តែដឹងអញ្ចឹងទេ ។

ប៊ុនថន : បាទៗ!

ខន : អាគេចល័តម៉ង ក្នុងតំបន់ៗកំពង់ស្ពឺខាងជើង ខាងត្បូង ទៅតាកែវ កំពតគេចង់ទៅវៃ ខាងណាគេចល័ត ដោយឡែកតែតំបន់អត់មានចល័តទៅខាងណាទេ សម្រាប់តែតំបន់ខ្ញុំ គឺចល័តបានតែត្រឹមហ្នឹង ត្រឹមថ្នល់ជាតិលេខ តាមផ្លូវជាតិលេខ៤ខាងជើង ហើយ តំបន់៣៣ខាងត្បូងគេ ខាងត្បូងគាត់បើយើងចង់ពិភាក្សាជាមួយគ្នា សហការគ្នាយើង ចាប់ដៃគ្នាវៃដូចថា វៃម្ដុំត្រពាំងក្រឡឹងអីហ្នឹង យើងចាប់ដៃគ្នាថ្នល់ជាតិហ្នឹងបាន ហើយណាយើងត្រូវសហការណ៍គ្នាវៃថាផ្លូវថ្នល់ជាតិតំបន់ថ្នល់ជាតិលេខ៤អញ្ចឹងទៅ ៣៣គេ ខាងនោះគេចង់ទាកលទងយើងវៃលូដែកហ្នឹង គេម៉ោចាប់ដៃយើងហ្នឹងគេថាវៃ ដែកនេះ យើងចាប់ដៃគ្នាបាន ។

ប៊ុនថន : បាទ!តំបន់ពូហ្នឹងនៅភូមិភាគអីវិញ បញ្ចឹម?

ខន : បញ្ចឹម បាទ!តំបន់ខ្ញុំហ្នឹងតំបន់៣២ហ្នឹងនៅភូមិភាគបញ្ចឹម ខាងជើង កំពង់ស្ពឺដែរតែ កំពង់ស្ពឺខាងជើង ។

ប៊ុនថន : បាទ!ជាប់ម៉ោកំពង់ឆ្នាំង?

ខន : បាទៗ!ជាប់ម៉ោកំពង់ឆ្នាំង ជាប់ម៉ោភូមិភាគពិសេសទៀត ភូមិភាគពិសេសគេចាប់ពី បាត់ដឹងអីហ្នឹងអាហ្នឹងភូមិភាគពិសេសហើយ ម៉ោលិចនេះម៉ោចន្ទខ្មៅៗ ម៉ោវាលពន្ធអី ហ្នឹងប្អូនដែលទៅទេ?

ប៊ុនថន : បាទ!ខ្ញុំអត់ដែលចូលទៅដល់ទេ?

ខន : អាហ្នឹងក្នុងតំបន់៣២ហើយ ចន្ទខ្មៅ វាលពន្ធ ក្រាំងចេក ម៉ោក្រោយម៉ោ ។

ប៊ុនថន : អមលាំងអី?

ខន : បាទ!អមលាំងអីនៅតំបន់៣២ទាំងអស់ កំពង់ស្ពឺក៏៣២ដែរ មកទល់ភ្នំស្រួចៗខាងជើង ហ្នឹងក្រាំងនីរ៉ាយ ប្រហក់គីរីរម្យខាងជើងហ្នឹង អាហ្នឹងស្រុកកំណើតខ្ញុំហ្នឹងនៅកំបង់ស្ពឺ ទាំងអស់ ។

ប៊ុនថន : បាទ!អញ្ចឹងម៉ា៣២ហ្នឹងពូនៅជុំវិញហ្នឹងម៉ង?

ខន : បាទ!នៅម៉ាជុំវិញហ្នឹង ។

ប៊ុនថន ៖ ចុះលោកពូ នៅនោះឆ្នាំសម័យតស៊ូ៥ឆ្នាំនោះដូច ឌុចអីគាត់ទៅខាងនោះដែរពូ?

ខន ៖ អត់សូវស្គាល់ ដូចអត់ដែលម៉ោទេ តែទៅក៏អត់ដែលស្គាល់ដែរ ។

ប៊ុនថន ៖ វាខុសគ្នាពូ?

ខន ៖ បាទ!ដូចវាខុសគ្នា ដូចមិនដែលស្គាល់គាត់ផង ឌុច ហ្នឹងអត់ដែលស្គាល់ទេទឹមខ្ញុំឃើញតាមរូបថតអី ទៅហ្នឹងដែលស្គាល់បំផុតមានតែភូមិភាគហ្នឹងគឺ តាស៊ីវ ហើយបើមេទ័ពហ្នឹងដែលអប់រំតំបន់ អប់រំភូមិភាគ អប់រំពួកទ័ពស្រួចទ័ពអីហ្នឹងឲ្យរៀនចំរុះគ្នា ជ្រើសរើសដូចឧបមាថា អូនជាអនុសេនាធំកងវរៈ ខ្ញុំកងវរៈអញ្ចឹងគេត្រូវបើកវគ្គមានតែតាម៉ុក ។

ប៊ុនថន ៖ បាទ!

ខន ៖ បាទ!ឃើញតែតាម៉ុកហ្នឹង តាប៊ិតហើយតាមុត ។

ប៊ុនថន ៖ បាទ! សំ ប៊ិត ហ្នឹង?

ខន ៖ បាទ! សំ ប៊ិតហ្នឹងហើយនាគ មុតនោះ មានតែ៣-៤នាក់ហ្នឹងទេដែលគាត់អប់រំអំពីយុត្តិសាស្ត្ររបៀបម៉េច បទពិសោធន៍វ៉ៃ ឧទាហរណ៍ ខាងភូមិភាគយើងគេវ៉ៃនៅតាមផ្លូវជាតិលេខ៤ មូលហេតុអីបានបាកក់ ហើយខាងតំបន់នានាវ៉ៃខាងកំពង់ស្ពឺហ្នឹងមូលអីបានយកជ័យជំនះ គេដកពិសោធន៍ម៉ាអាទិត្យអីអញ្ចឹង រៀនចំរុះគ្នា មាន នាគ មុត ហើយ សំប៊ិត ហ្នឹងឯង តាម៉ុកហ្នឹងគាត់ ហើយលើកយកយុត្តិសាស្ត្រវ៉ៃទៀត ត្រូវវ៉ៃរបៀបម៉េចតទៅទៀត យើងត្រូវវ៉ៃយ៉ាងម៉េចការពារកុំឲ្យមានគ្រោះថ្នាក់ កម្លាំងកុំឲ្យបាត់បង់ពាក់លីជីវិតអីច្រើន យើងត្រូវធ្វើសង្គ្រាមរបៀបម៉េច ប្រើរបៀបម៉េចអាហ្នឹងជាយុត្តិសាស្ត្រអ្នករៀនសូត្រ ។

ប៊ុនថន ៖ បាទៗ!

ខន ៖ ជាគោលនយោបាយ អប់រំនយោបាយឲ្យកម្មាភិបាលទាំងអស់ត្រូវចេះ ពីដើមគេហៅថាមេទ័ពទាំងអស់ត្រូវចេះយកចិត្តទុកដាក់ជាមួយយុទ្ធជន ស្រឡាញ់យុទ្ធជន ស្លាប់រស់ជាមួយគ្នា កុំរត់ចោលគ្នា មានរបួសហើយកុំចោលរបួសដាច់ខាត គឺយកឲ្យបានបានហើយហ្នឹង អប់រំម៉ោវិញថែទាំគ្នាឲ្យដល់ពេទ្យ ដើម្បីយើងរក្សាកម្លាំងថាជាគោលនយោបាយអប់រំខាងផ្លូវព្រះធម៌ មេទ័ពមួយៗត្រូវឈានមុខមុនគេ ដឹកនាំយុវជនគឺត្រូវក្លាហានមុនគេកុំឲ្យជម្លៀសយុវជនទៅគេខ្ញុំណាស់ នៅក្រោយអត់ព្រមទៅ ។

ប៊ុនថន ៖ ហើយចូលទៅវ៉ៃមុនគេ?

ខន ៖ បាទ!ចូលទៅវៃ ឲ្យបងប្អូនចូលទៅវៃមុនគ្រោះថ្នាក់ហើយបោលគេអត់បានទេ ។

ប៊ុនថន ៖ បាទ!

ខន ៖ បាទ!ឧបមាថាខ្ញុំអនុសេនាធំអញ្ចឹង ខ្ញុំចូលទៅវៃបន្ទាយហ្នឹងមួយ ឲ្យបងប្អូនទៅ ហើយខ្ញុំអត់ទៅអត់បានទេ ខ្ញុំត្រូវដឹកនាំទៅជាមួយ បើមានការគ្រោះថ្នាក់ទាហានបាញ់របួសអត់ឲ្យចូលទេ សុខចិត្តទៅយកឲ្យបានម៉ោក្រោយ ។

ប៊ុនថន ៖ បាទ!

ខន ៖ បាទ!យកមកដល់ពេទ្យ ។

ប៊ុនថន ៖ អញ្ចឹងមានតែតាម៉ុកអីខស្សហ៍ទៅប្រជុំដកពិសោធន៍កងទ័ពដែរ?

ខន ៖ បាទ!ខស្សហ៍ទៅប្រជុំ ។

ប៊ុនថន ៖ ចុះតា ស៊ី អី?

ខន ៖ តាស៊ីវ ជាភូមិភាគហ្នឹង ក្រោយមកគេបែក អាហ្នឹងតាម៉ុកខាងយោធា ។

ប៊ុនថន ៖ បាទ!

ខន ៖ ដល់ក្រោយម៉ោតាស៊ីវគេខាងភូមិភាគ តាស៊ីវគេទៅត្រឹមថ្នាក់តំបន់ ឬក៏វរៈសេនាធំ ត្រឹមថ្នាក់ខ្ញុំអី ជាអនុសេនាធំអីមិនសូវដែលបានទេ ព្រោះចុះម៉ោហួស កាលចុះសមរភូមិកាលហ្នឹង អាហ្នឹងចង់និយាយកាលពីនៅសង្គ្រាម ។

ប៊ុនថន ៖ បាទៗ!

ខន ៖ ចុះសមរភូមិគេត្រឹមកងវរៈចាប់ពីប្រធាន ពីដើមយើងអត់រៀនដូចឥឡូវទេ ព្រោះវាមានស្នងការ នយោបាយ បញ្ជាការ សេដ្ឋកិច្ច ។

ប៊ុនថន ៖ បាទៗ!

ខន ៖ មិនដូចឥឡូវសេនាធិការគេរៀបចំ ម៉េចខ្ញុំអត់សូវយល់ទេ ។

ប៊ុនថន ៖ បាទ!កាលមុនមានន៣ ពូ?

ខន ៖ បាទ!មានន៣ មានននយោបាយ យោធា និងសេដ្ឋកិច្ច បាទ!អាហ្នឹងហើយ៣ៗនាក់ទទួលបន្ទុកហ្នឹង ដូចថាពេលដែលអញ្ចឹងដូចថាកងវរៈអញ្ចឹងយោធាចេញទៅឈរមុខ បន្តស់ហើយស្នងការគេនៅក្រោយ សម្រាប់បញ្ជូនអីៗ រៀនសូត្រអី យោធា បញ្ជាជាមួយអនុសេនាធំម៉ោមុខ កងអនុសេនាតូច មេក្រុមអីនៅមុខទាំងអស់ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងលោកពូខាងស្នងការ ខាងពីណាវិញ?

ខន :	ខ្ញុំដែលអនុសេនាធំហ្នឹងខ្ញុំទទួលខាង មុនដំបូងពីឆ្នាំ៧៣ ខ្ញុំទទួលបញ្ជា ក្រោយម៉ោខ្ញុំទទួលស្នងការ ៧៣ចុង៧៣អីហ្នឹងខ្ញុំទទួលខាងស្នងការ ។

ប៊ុនថន :	ចុះដូរពីណាទៅខាងណាវិញ បញ្ជា?

ខន :	បញ្ជាឲ្យឈ្មោះសុខ ខន វិញ ខ្ញុំជ័យ ខន គេសុខ ខន គេជាបញ្ជាវិញ ហើយខ្ញុំជាស្នងការ ។

ប៊ុនថន :	អញ្ជឹងដូរគ្នា២នាក់គាត់ហ្នឹង?

ខន :	ដូរគ្នា មេគេពីលើគេដូរម៉ោ ។

ប៊ុនថន :	ចុះខាងសេដ្ឋ?

ខន :	សេដ្ឋកិច្ចខាងអនុសេនាធំខ្ញុំហ្នឹងឈ្មោះ ម៉ន ។

ប៊ុនថន :	បាទ!

ខន :	បាទ!ឈ្មោះ ម៉នៗហ្នឹងវាអឹមអាវទៅ ឲ្យគាត់ទទួលបាយទឹកអី ឲ្យបញ្ជូនបាយបញ្ជូនទឹកទៅតាមរយៈកម្លាំងដែលអត់ៗល្មមអាចនឹងទៅរែកបាយរែកអីយកទៅខ្ញុំនៅខាងមុខ ។

ប៊ុនថន :	បាទ!

ខន :	បាទ!រែកគ្រាប់រំសេវអីមួយចំនួន អាហ្នឹងខ្ញុំសុទ្ធតែមានមតិខ្ញុំ ។

ប៊ុនថន :	បាទ!ហើយពេលឆ្នាំ៧៥ពូមានបានវៃចូលភ្នំពេញអីដែរទេ លោកពូ?

ខន :	បាទ!កាលពី៧៥ខ្ញុំអត់ទេ ខ្ញុំនៅកំពង់ស្ពឺ វៃចូលកំពង់ស្ពឺហ្នឹង ។ ឆ្នាំ៧៥ហ្នឹងខ្ញុំវៃនៅពីខាងជើងកំពង់ស្ពឺហ្នឹង កំពង់ស្ពឺនៅក្រុងកំពង់ស្ពឺប៉ុនដែលស្គាល់គេដង ពីព្រោះមិនដែលនៅជិតក្រុងគេណា៎ នៅជិតគីរីរម្យនេះ ដល់វៃក្រុងកំពង់ស្ពឺគេថាអាហ្នឹងក្រុងកំពង់ស្ពឺ ដល់រួចច្បារម៉នវានៅពីខាងលិច ហើយខ្ញុំចូលពីជើងៗទៅវៃកំពង់ស្ពឺហ្នឹងបានស្គាល់ផ្សារកំពង់ស្ពឺហ្នឹងឃើញផ្ទះថ្ម ដល់អញ្ជឹង៧៥វៃរំដោះម៉ោ បានឮដំណឹងថានៅភ្នំពេញនោះគេជិតលើកដៃហើយ ។

ប៊ុនថន :	បាទ!

ខន :	ហើយយើងនេះក៏យើងលើកដៃវៃសំរុក យើងនៅនេះក៏មិនបាច់វៃអីដែរ យើងនៅនេះក៏ជិតលើកដៃដែរ នៅនោះលើក បើខាងនោះចាញ់នៅនេះក៏លើកដៃចូលក្រុងកំពង់ស្ពឺទៅ ។

ប៊ុនថន :	បាទ!កាលហ្នឹងពូវៃចូលកំពង់ស្ពឺ?

ខន :	បាទ!វៃចូលកំពង់ស្ពឺ ។

ប៊ុនថន : ហើយខាងភូមិភាគនេះគេវៃចូលភ្នំពេញពូ?

ខន : បាទ!ខាងភូមិភាគគេវៃចូលភ្នំពេញ ហើយខាងតំបន់តាមខេត្ត ។

ប៊ុនថន : បាទ!កាលហ្នឹងភូមិភាគបញ្ចឹមមានប៉ុន្មានកងពល កាលហ្នឹងពូ?

ខន : ភូមិភាគបញ្ចឹម បើតាមខ្ញុំដឹងកាលហ្នឹងដូចបើមិន២ក៏៣ កងពលទី១ ទី២ ទី៣ ដូច៣ ។

ប៊ុនថន : ៣កងពល?

ខន : ៣កងពល ។

ប៊ុនថន : អញ្ចឹងពូមានស្គាល់នេះទេ មាស វឿន ៗហ្នឹងគាត់ខាងកងពលដែរខាងបញ្ចឹម?

ខន : អត់ស្គាល់ទេ គេខាងកំពង់ឆ្នាំង ។

ប៊ុនថន : បាទៗ!ប្រហែលជានៅម្តុំកំពង់ឆ្នាំង?

ខន : អត់ស្គាល់ទេខ្ញុំ ត្រឹមថ្នាក់ខ្ញុំអីជាអនុសេនាធំអីមិនស្គាល់អស់ផង ។

ប៊ុនថន : អត់ស្គាល់អស់ទេ?

ខន : បាទ!អត់បានដើរទេអូន អត់បានដើរនិយាយម៉ាមាត់គឺអត់បានដើរទៅណាទេ បើក្រោយជួបតែមេវរៈសេនាធំ អីហ្នឹងបាន២ម៉ាត់២ម៉ោង ទៅនៅជាមួយកូនទាហាន នៅជាមួយហ្នឹងអត់ចោលអត់បានទេ ។

ប៊ុនថន : អត់ចោលបានទេ?

ខន : វាទៅជាប់ហ្នឹងម៉ង់ គ្រុនឈឺអី ក្បួនថ្នាំអីនៅហ្នឹង និយាយរួមម៉ោក្រោយអត់បាន ម៉ោក្រោយបាន ភូតប្រជាជនអីបានម៉ោ៣ថ្ងៃអីហ្នឹងបានជួយស្ទុងជួយដកអីប៉ុណ្ណឹង ទៅវិញបាត់ហើយ ។

ប៊ុនថន : ត្រឡប់ទៅវិញ?

ខន : បាទ!

ប៊ុនថន : ចុះពេលវៃចូលកំពង់ស្ពឺហ្នឹងវៃប៉ុន្មានថ្ងៃចូល?

ខន : វៃចូលកំពង់ស្ពឺហ្នឹងខ្ទង់ម៉ាអាទិត្យអីនោះបានចូល មុនដំបូងទំរាំព្រភ្នំពេញនោះថ្ងៃ១៧ ហ្នឹងត្រូវគេលើកដៃលើកអីហ្នឹង យី!វៃម៉ាអាទិត្យអី វៃចូលជិតកន្ទះខែនោះ យើងវៃពីចន្ងាយអញ្ចឹងទៅ ទប់ទល់គ្នាៗ មួងគេ គេនោះលើកដៃខាងភ្នំពេញនោះលើកដៃថាសុំចុះចាញ់ បាននេះលើកទាំងអស់គ្នាទៅ ។

ប៊ុនថន : បាទ!ចុះពេលខាងកំពង់ស្ពឺ ពេលដាច់ហើយហ្នឹងពូនៅកំពង់ស្ពឺដដែលឬស្នាក់នៅ?

ខន : បាទ! ពេលគេកំពុងតែលើកដៃខ្ញុំនៅកំពង់ស្ពឺ តែនៅក្នុងក្រុង អញ្ចឹងមានផែនការណ៍អង្គការគេផ្ទាក់លើគេឲ្យប្រជាជនក្នុងក្រុងចេញ គេឲ្យចេញ ឲ្យទ័ពទៅនៅ ។

ប៊ុនថន : បាទ!

ខន : ឲ្យទៅនៅហ្នឹង ឲ្យប្រមូលសំភារៈទុកដាក់ឲ្យបានស្រួលបួលតាមឃ្លាំង តាមអីទេ មើលរបស់របរអីប្រមូលទុកដាក់តាមឃ្លាំងហ្នឹង ទ័ពនៅការពារ បាទ! នៅបាន៣ខែ ក៏ខាងតំបន់ហ្នឹងគេឲ្យខ្ញុំចុះម៉ោជួយលើកទំនប់ លើកការដ្ឋានជាមួយប្រជាជន ជាមួយកសិករជាមួយសហករណ៍គេណា៎ ។

ប៊ុនថន : បាទ!

ខន : ហើយខ្ញុំម៉ោចាំថ្នាលនេះ សុំឲ្យទ័ពម៉ោម៉ាកង១ម៉ោជួយ ។

ប៊ុនថន : ចុះពូម៉ោៗអនុសេនាធំនេះ?

ខន : ខ្ញុំម៉ោពីអនុសេនាធំ ខ្ញុំឡើងដល់វរៈហើយ ។

ប៊ុនថន : អ្ហូ! ឡើងដល់វរៈហើយ?

ខន : ដល់អញ្ចឹងមុនឈ្មោះហ្នឹង ខ្ញុំឡើងវរៈដែរ ហើយខ្ញុំទទួលជាអនុទេ បានទទួលជាអនុវរៈហ្នឹងវរៈ១៣៨ ។

ប៊ុនថន : ១៣៨?

ខន : បាទ! ហើយដល់អញ្ចឹងខ្ញុំម៉ោចាំថ្នាលនេះ ម៉ោលើកទំនប់ចាំថ្នាលយើងនៅខាងជើងកំពង់ស្ពឺនេះអូន ។

ប៊ុនថន : បាទ!

ខន : ម៉ោជាមួយប្រជាជនគេហ្នឹង លើកទំនប់ហ្នឹងខ្ញុំហ្នឹងខាងតំបន់ឲ្យម៉ោចូលរួម គាត់ឲ្យម៉ោធ្វើម៉េចឲ្យម៉ោរស់នៅជាមួយប្រជាជនឲ្យបានស្រួល ហើយប៉ុនឲ្យប្រុងប្រយ័ត្ន ។

ប៊ុនថន : បាទ!

ខន : បាទ! ក្រែងមានខ្មាំងសត្រូវអីប៉ុនប៉ងអីឲ្យប្រយ័ត្ន ប្រយ័ត្នហ្នឹងខ្ញុំទាំងអស់គ្នាអត់មានប្រយ័ត្នអីទេ គ្រាន់តែកាំភ្លើងកុំទុកប្រហែល យើងទុកឲ្យមានកន្លែងឧទាហរណ៍ថាខ្ញុំទៅពីអនុសេនាធំអញ្ចឹងមានទីតាំងខ្ញុំទុកកាំភ្លើង ហើយយើងត្រូវដាក់អ្នកការពារឲ្យបានស្រួលបួល ហើយក្រៅពីហ្នឹងទៅលើកទំនប់ លើកប្រឡាយជាមួយប្រជាពលរដ្ឋ ។

ប៊ុនថន : បាទ!

ខន ៖ បាទ!ខ្ញុំនៅហ្នឹងក៏ទៅដឹកនាំធ្វើជាមួយគេទាំងអស់ដែរ ដល់ម៉ោងម៉ោហូបបាយខ្លួនឯងទៅ ដាំបាយខ្លួនឯងទៅ ។

ប៊ុនថន ៖ បាទ!កាលហ្នឹងនៅ តាប៉ាវ ដដែល?

ខន ៖ នៅតាប៉ាវ ដដែល តាប៉ាវ តាកន តាកន ទទួលដែរ តាប៉ាវប្រហែលជាគាត់លែង ត្រៀមលែងភាគហើយ ។

ប៊ុនថន ៖ អ្ហូ!ត្រៀមឡើងដែរ?

ខន ៖ បាទ! តែខ្ញុំវាមិនសូវដឹង ខ្ញុំវាថ្នាក់ក្រោមមិនសូវដឹងគេទេ ប៉ុនគាត់ត្រៀមឡើងភាគ តាកនគាត់ទទួលតំបន់ ។

ប៊ុនថន ៖ បាទ!អញ្ជឹងពូដឹកប្រឡាយដឹកជាមួយប្រជាជន គាត់នាំដឹក?

ខន ៖ បាទ!ដឹកជាមួយប្រជាជនហ្នឹង លើកទំនប់ ទៅលើកដល់ម៉ោងដូចគេអញ្ជឹង ដឹកនាំ ប្រជាជនលើកជាមួយគាត់ហ្នឹង ដូចថាប្រជាពលរដ្ឋលើកហ្នឹងខ្ញុំក៏ទៅលើកហ្នឹង អត់មាន ថាទៅបញ្ជា ទៅត្រួតត្រាអីគាត់ទេ ។

ប៊ុនថន ៖ បាទៗ!

ខន ៖ ប៉ុនគ្រាន់តែយើងស្ដាប់មើលប្រជាពលរដ្ឋ គាត់ម៉េចៗយើងស្ដាប់មើលទៅ ប៉ុនមិន ដែលប៉ះពាល់អីគាត់ទេខ្ញុំ ។

ប៊ុនថន ៖ បាទ!ប៉ុន្តែអ្នកដូចថា អ្នកតវ៉ាអីដែរ ពេលថ្នាក់លើណែនាំថាមានខ្មាំងមានអី?

ខន ៖ ភាគច្រើន កាលហ្នឹងដូចគាត់ខ្លាចច្រើនណាស់ គាត់មិនសូវហានទេ ដូចថាគាត់វៀងខ្លាច យើង ខ្លាចពួកខ្មែរក្រហម ប៉ុនយើងអត់ដែលធ្វើអី ប៉ុនមានទ័ពស្រុកគេខ្វះ មានឈ្លប ស្រុកគេផ្សេងៗដែលគេចុះជាមួយខ្ញុំផ្សេង រីឯតំបន់ៗទៅជ្រលូកជាមួយហ្នឹង គ្រាន់តែ ទៅរួមជាមួយវា ប៉ុនក្នុងនោះមានទ័ពស្រុកគេនៅជាមួយប្រជាពលរដ្ឋហ្នឹង ឈប់អីនៅ ហ្នឹង អាហ្នឹងបានគាត់ខ្លាចយើង បើសម្រាប់យើងនៅនេះគាត់ថាប្រជាពលរដ្ឋអត់សូវ ខ្លាចនិយាយជាមួយយើងទេ យើងអត់ដែលទៅបញ្ជាឲ្យគាត់ថាលើកចេះលើកចុះផង បើគាត់លើកទៅនោះយើងលើកទៅនេះ ចែកគ្នាលើក ម៉ាប្លង់អញ្ជឹងយើងម៉ាប្លង់ៗម្នាក់ ទៅជួនកាលយើងលើកហើយមុនគាត់ទៅ ជួនកាលគាត់សរសើរថាអេស៎!ពួកក្មួយៗទ័ព លើកហើយមុន ចុះយើងប្រឹងខំឲ្យហើយដែរ ឧទាហរណ៍ ប៉ុន្មានម៉ែត្រៗអញ្ជឹង ១០០ - ៣០នាក់លើកទៅ ហើយជួនកាលគាត់ហើយមុនយើងដែរ ហើយយើងអេស៎!ចាញ់ គាត់ហើយ អាហ្នឹកលើកដាក់ស្ដែងហ្នឹងម៉ោ ។

ប៊ុនថន ៖ បាទ!ពូទៅនោះរយៈពេលប៉ុន្មានពូទៅ?

ខន ៖ ខ្ញុំទៅនោះរយៈពេល៥-៦ខែ ទៅជួយលើកចាំថ្នាល ក្រោយមកដកម៉ោវិញ ដកឲ្យខ្ញុំម៉ោនៅកំពង់ស្ពឺនេះបាន២ឬ៣ខែ បញ្ជូនខ្ញុំទៅស៊ឹងព្រៅ។

ប៊ុនថន ៖ ស៊ឹងព្រៅ?

ខន ៖ បាទ!ស៊ឹងព្រៅគិរីរម្យម៉ាវិរៈសេនាតូច១៣៨ហ្នឹង ឲ្យខ្ញុំទៅស៊ឹងព្រៅៗហ្នឹងខ្ញុំ។

ប៊ុនថន ៖ ខាងណាដកពូ?

ខន ៖ ខាងតំបន់ តំបន់ហ្នឹងក៏បញ្ជាពីភាគម៉ោដែរ ភាគសម្រេចឲ្យម៉ាវិរៈសេនាតូចខ្ញុំហ្នឹង ដកពីកំពង់ស្ពឺហ្នឹងទៅស៊ឹងព្រៅគិរីរម្យ ទៅប្រចាំការនៅហ្នឹងម៉ាវិរៈហ្នឹងវា៣អនុសេនាធំអូន។

ប៊ុនថន ៖ បាទ!

ខន ៖ មានខ្ញុំទៅផ្ទាល់ ២នាក់នឹងឈ្មោះ វីរៈៗហ្នឹង។

ប៊ុនថន ៖ វីរៈដែរ?

ខន ៖ បាទ!វីរៈហ្នឹងគាត់ទទួលជាមួយខ្ញុំហ្នឹង។

ប៊ុនថន ៖ បាទ!ខាងគិរីរម្យហ្នឹងនៅក្នុងតំបន់៣២ដែរ?

ខន ៖ នៅក្នុងតំបន់៣២ដែរ នៅខាងលិចស្ពឺហ្នឹង។

ប៊ុនថន ៖ បាទៗ!

ខន ៖ ពីពេជ្រនិលស៊ឹងព្រៅហ្នឹង ខ្ញុំម៉ោចាប់នៅពីពេជ្រនិលស៊ឹងព្រៅ គិរីរម្យ ចំបក់។

ប៊ុនថន ៖ អ្ហូ!អញ្ចឹងវាយ?

ខន ៖ បាទ!វាយ ៣អនុសេនាធំហ្នឹងវាយគ្នា។

ប៊ុនថន ៖ អាហ្នឹងដាក់វាយការពារពូ?

ខន ៖ បាទ!ចេះវាយហ្នឹងការពារផ្លូវលេខ៤ផង ហើយទៅផលិតតែផង អាតែនៅវាលអាតែចាស់ហ្នឹង។

ប៊ុនថន ៖ បាទ!

ខន ៖ បាទ!នៅចំការតែហ្នឹងពីមុនតំបន់គេរៀបចំកម្លាំងនៅហ្នឹង៩០នាក់ នារីយុវជន មានបងម្នាក់គាត់នៅទទួលហ្នឹង ដល់អញ្ចឹងប្រគល់ឲ្យខ្ញុំ ប្រគល់ឲ្យខ្ញុំទ័ពហ្នឹងទៅគិរីរម្យហ្នឹង ផលិតតែផងបញ្ជូនម៉ោតំបន់ម៉ោឲ្យភូមិភាគ នៅកំពង់ស្ពឺនោះ ហើយស៊ឹងប្រាលខ្ញុំមានភារៈកិច្ចទៅការពារជាមួយនឹងភូមិភាគ ពីភូមិភាគពីភ្នំពេញម៉ោ អាហ្នឹងគេភូមិភាគហើយគេ ពីភ្នំពេញម៉ោៗអនុសេនាធំគេ គេម៉ោកងវិរៈគ្នាគេ២នាក់ ម៉ោហ្នឹងការពារស៊ឹងព្រៅហ្នឹង

ខ្ញុំក៏មានភារៈកិច្ចទៅស៊ីងប្រៅ ពីភ្នំពេញម៉ោភូមិភាគគេពីភ្នំពេញម៉ោក៏គេម៉ោការពារនៅស៊ីងប្រៅហ្នឹង ។

ប៊ុនថន : ភូមិភាគប៉ុន្មានវិញម៉ោភ្នំពេញពូ?

ខន : ខ្ញុំភ្លេចហើយ ខាងភ្នំពេញហ្នឹងគេម៉ោខាងកងទ័ពនៅភ្នំពេញហ្នឹង គេហៅកងទ័ពស្រួចវាទ័ពបដ្ឋមគេ ។

ប៊ុនថន : ទ័ពបដ្ឋម អញ្ចឹងអត់មានចំណុះភូមិភាគណាទេ?

ខន : អត់មានចំណុះភូមិភាគទេ តាមមើលទ័ពបដ្ឋមម៉ង ។

ប៊ុនថន : នៅក្រោមសេនាធិការគ្រប់គ្រង?

ខន : បាទ!នៅក្រោមសេនាធិការ គេម៉ោមាអនុសេនាធំ ៦ខ្ញុំនេះមាអនុសេនាធំក៏ទៅនៅជាមួយហ្នឹងដែរ ខាងតំបន់ ការពារវ៉ារីអគ្គិសនីនៅប្រៅព្រោះរាជគេម៉ោធ្វើ ។

ប៊ុនថន : អ្ហូ!

ខន : បាទ!ម៉ោជួសជុលអាស្ពានវ៉ារីនៅ អ្ហូ!មិនមែនស្ពានទេ ម៉ោជួសជុលអាវ៉ារីអគ្គិសនីនៅស៊ីងប្រៅ គេហៅយូហ្គោស្លាវីធ្វើ ។

ប៊ុនថន : បាទ!

ខន : អាហ្នឹងខ្ញុំនិយាយឲ្យវែងបន្តិចចុះ ។

ប៊ុនថន : បាទ!អត់អីលោកពូ រៀបរាប់ឲ្យច្បាស់ ។

ខន : បាទ!ទៅការពារហ្នឹង ការពារកូរ៉េ បាទ!ធ្វើម៉េចកុំឲ្យមានការគ្រោះថ្នាក់ដល់ខ្មាំង ឬក៏ខ្មែរសខ្មែរអីម៉េច ចូលបាញ់ចូលធ្វើគ្នាយើង ដើរទៅជាមួយគេទាំងអស់ដើរការពារហើយធ្វើជាមួយគេខ្លះ ។

ប៊ុនថន : អញ្ចឹងពូខាងកូរ៉េហ្នឹង កូរ៉េខាងជើង?

ខន : បាទ!កូរ៉េខាងជើង កូរ៉េខាងត្បូងគេមិនដែលម៉ោទេ កូរ៉េខាងជើងគេធ្វើជិតហើយ ធ្វើហ្នឹងគេដាក់ថែមអីទាំងអស់ ជិតប្រើប្រាស់ហើយក៏សភាពការណ៍អញ្ចឹងទៀតទៅហើយខ្ញុំទៅនៅនោះបាន២ឆ្នាំ ខ្ញុំចល័តខ្ញុំនៅគិរីរម្យផង ទៅស៊ីងប្រៅផង ម៉ោចំបក់ដងរហូតម៉ោដល់៧៩ ។

ប៊ុនថន : ច្រើនទេពូកូរ៉េទៅធ្វើនៅនោះ?

ខន : កូរ៉េទៅធ្វើនៅនោះវាខ្ទង់៥០នាក់ ។

ប៊ុនថន : ៥០នាក់?

ខន ៈ បាទ!៥០នាក់ កម្មករលើវ៉ាតាំងអស់ បាយទឹកអីគឺខ្មែរយើងដាំឲ្យ ប៉ុន្តែគេជ្រើសរើសពីភ្នំពេញម៉ោ ហើយកម្លាំងខាងបញ្ជីមយើងហ្នឹង គឺខ្មែរគេម៉ោគេសម្រាប់ថាខាងក្រសួងការងារបរទេសគេហ្នឹងគេប៉ុន្មាននាក់ហ្នឹងគេនៅក្នុង ដល់ពេលខ្ញុំអត់មាន ទាល់តែមាអាទិត្យអីនុះបានគេហៅទៅប្រជុំគណៈសភាពការណ៍រួមសមាសភាពការណ៍ យើងរាយការណ៍ខាងក្រោយ សន្តិសុខអីអត់អីទេ ហើយយើងគេធ្វើរបៀបម៉េចអីរបៀបម៉េចអាហ្នឹងគេហៅខាងខ្ញុំប្រជុំម្តង ។

ប៊ុនថន ៈ ខាងណាអ្នកម៉ោប្រជុំពូ?

ខន ៈ ខាងមជ្ឈឹមគេហ្នឹង ។

ប៊ុនថន ៈ ពីណាៗកាលហ្នឹង?

ខន ៈ អ៊ើ!លី ហ៊ូវ បងលី ហ៊ូវ ។

ប៊ុនថន ៈ គាត់នៅរស់ទេសព្វថ្ងៃ?

ខន ៈ អត់ទេ!លី ហ៊ូវ ហ្នឹងស្លាប់ហើយ ។

ប៊ុនថន ៈ លី ហ៊ូវហើយពីណាទៀត?

ខន ៈ អត់ស្គាល់ភ្លេចបាត់ហើយ ។

ប៊ុនថន ៈ លី ហ៊ូវ ហ្នឹងពីមុនគាត់ធ្វើអីដែរ?

ខន ៈ គាត់នៅខាងមជ្ឈឹម នៅខាងក្រសួងការពារបរទេសមិនដឹង ឬក៏ខាងទ័ពទេ ប៉ុនទ័ពក៏គេគ្រប់គ្រង ហើយក្នុងគីរីហ្នឹងក៏គេគ្រប់គ្រងដែរ ។

ប៊ុនថន ៈ បាទ!

ខន ៈ បាទ!អញ្ចឹងបានន័យថាគេចាត់ចែង ដឹកសំភារៈអី ម៉ោហូបចុកអីនៅលើវ៉ាតាំងអស់ហ្នឹងគ្រប់គ្រង ឯខ្ញុំគ្រាន់តែនៅជិតគេ ប៉ុន្តែគ្រាន់តែជួយការពារទេ ។

ប៊ុនថន ៈ បាទ!

ខន ៈ បាទ!ហើយគ្រាន់តែទៅប្រជុំគេគណៈបញ្ជាការទៅហៅ១ដងទៅ មាអាទិត្យឬ២អាទិត្យគេហៅទៅប្រជុំម្តងទៅសភាពការណ៍យ៉ាងម៉េចអីយ៉ាងម៉េចរាយការណ៍គេ ធ្វើរបាយការណ៍អញ្ចឹងទៅ បានមានតែប៉ុណ្ណឹងទេ ។

ប៊ុនថន ៈ ពូនៅនោះ ការពារកន្លែងវ៉ារីអគ្គិសនីហ្នឹងផង នៅផ្លូវជាតិលេខ៤ផង?

ខន ៈ បាទ!នៅតាមផ្លូវជាតិលេខ៤ផង ការពារ កាលហ្នឹងយើងការពារផ្លូវជាតិលេខ៤ហ្នឹងវ៉ាស្ងាត់ ឡានចេញចូលអីយើងការពារ ចាប់ពីពេជ្រនិលទៅរហូតខ្ញុំការពារកាលហ្នឹង ។

ប៊ុនថន :	បាទ! អញ្ចឹងសំភារៈអីដឹកចូលតាមផ្លូវជាតិលេខ៤?

ខន :	បាទ! ដឹកពីភ្នំពេញទៅដែរ អ្ហូ! កំពង់សោមក៏ចេញម៉ោ អាពីភ្នំពេញខាងខ្ញុំខុត្តម គេដឹកយកទៅពីកំពង់ស្ពឺទៅឲ្យអង្គរកូរ៉េ បើខាងពីមជ្ឈិមវិញគេដឹកពីកំពង់សោម ហើយលូអីដែលត្រូវជួសជុលលូអីហ្នឹង កូរ៉េដឹកពីដឹកកំពង់សោមម៉ោ អាលូក្រហមធំៗនោះ ជំនាន់កាលហ្នឹងដាក់ពីស្ទឹងប្រាលមកក្រោមអី ។

ប៊ុនថន :	ចុះនៅកំពង់សោមហ្នឹងដូចខាងជើងទឹក ជើងអីហ្នឹងទាក់ទងគ្នាដែរជាមួយខាងពូទេពូ?

ខន :	ខាងជើងទឹកអីឆ្ងាយពីគ្នាណាស់អូន ខាងតំបន់ កាលហ្នឹងវារំលងតំបន់ អញ្ចឹងគេទាក់ទងមកខាងតំបន់កោះកុងអីហ្នឹង គឺមានកងពលភូមិភាគបញ្ចឹមអីហ្នឹងគេទៅប្រចាំការណ៍នៅហ្នឹងអញ្ចឹង គេអាចម៉ោជួបយើងដដែកក្របខណ្ឌនៅកំពង់សិលាអីអញ្ចឹងទៅណា៎ ។

ប៊ុនថន :	បាទ!

ខន :	បាទ! ដែលធ្វើការខាងកងពលទី១ហ្នឹងគេធ្វើម៉ោពីនោះម៉ោ ខាងខ្ញុំហ្នឹងធ្វើទៅហ្នឹងយូរៗចាប់ដៃគ្នាម្តងទេអត់សូវមានអីទេ ។

ប៊ុនថន :	បាទ! ចុះពូខាងភូមិភាគបញ្ចឹមហ្នឹងមានតំបន់អីខ្លះ តំបន់៣២ តំបន់ប៉ុន្មានទៀត កាល ហ្នឹង?

ខន :	តំបន់ភូមិភាគបញ្ចឹម មានតំបន់៣១ តំបន់៣២ តំបន់៣៣ ។

ប៊ុនថន :	៣១-៣២-៣៣?

ខន :	បាទៗ! ៣៣ហ្នឹងខាងកោះកុងហើយ ៣១កំពង់ឆ្នាំង តាមខ្ញុំដឹង ៣២កំពង់ស្ពឺខាងជើង មានអា៣១ខាងត្បូងនោះគេផ្សេងទៀត ។

ប៊ុនថន :	ចុះខាងព្រៃនប់ ព្រៃអីនោះ៣០ប៉ុន្មាន?

ខន :	ព្រៃនប់ៗអាហ្នឹងខាងៗ ខាងអីទេខ្ញុំភ្លេចហើយ អាហ្នឹង ។

ប៊ុនថន :	ខាងស្រែអំបិល ឬខាងអីលោកពូ?

ខន :	បាទ! ដូចស្រែអំបិលហ្នឹង កោះកុងហើយ ដូច៣៣អញ្ចឹង ។

ប៊ុនថន :	៣៣?

ខន :	បាទ!

ប៊ុនថន :	កាលហ្នឹងខាងអ្នកណាគ្រប់គ្រងវិញ ខាងតំបន់៣៣ហ្នឹង?

ខន :	អ្ហូ! អត់សូវដឹងផងកាលហ្នឹង ឃើញតែគេដកហូតៗមិនដឹងខាងណាៗខ្ញុំមិនសូវដឹងគេ ទេ និយាយមួយម៉ាត់ទៅវាមិនសូវដឹងទាំងអស់ម៉ង ខ្ញុំហ្នឹងវានៅតែមួយកន្លែងហ្នឹង ហើយ បើទ័ពខ្ញុំពេលដែលខ្ញុំទៅគ្រប់គ្រងសុទ្ធគ្នាមានកំហុសទេអូន នាំគ្នាកាប់តែចំការហ្នឹងដាំអី

ហូបហ្នឹង អត់មានដឹងអីទេ ដឹងតែថាម៉ោលេងពុកម៉ែមួយដងៗហ្នឹងឃើញតែគាត់ធ្វើស្រែធ្វើអីហ្នឹងយ៉ាប់ណាស់ ដល់ខ្ញុំនេះដូចអត់យ៉ាប់ ដាំដុះខ្លួនឯងបានហូបខ្លួនឯង ជីវភាពខ្លួនឯងដូចអត់យ៉ាប់ ឮតែគាត់ថា បាយរួមបាយអីពិបាកអាណិតគាត់ដែរ ម្ដាយឪពុកពេលដែលខ្ញុំមៅជួបម្ដងៗម៉ោជួបគ្នា ខ្ញុំមិនដែលហាននិយាយអីដែរ មិនដឹងថា ម៉េចធ្វើស្រែអីស្អួងមួយថ្ងៃៗអត់ទំនេរទេ ធ្វើដីធ្វើអី ខ្ញុំអត់ដឹងទេខ្ញុំអត់បានទៅធ្វើ ស្រែទេខ្ញុំធ្វើតែចំការស្រូវខ្ញុំ ប្អូនៗហូបតាមចិត្តដាក់ជង្រុកយ៉ាងណាទេ ។

ប៊ុនថន : ហើយលោកពូអត់ដែលឡើងម៉ោប្រជុំម៉ោអី?

ខន : បាទ!ឡើងម៉ោប្រជុំ មៅប្រជុំតែវរៈសេនាធំ ម៉ោកំពង់ស្ពឺមៅដែរ ។

ប៊ុនថន : បាទៗ!ប៉ុនម៉ោភ្នំពេញនេះអត់ដែលម៉ោទេ គេធ្វើខួបកងទ័ព?

ខន : អត់ទេ!ខ្ញុំអត់ដែលទេ ។

ប៊ុនថន : អត់ដែរ?

ខន : បាទ!ខ្ញុំបានមៅតែកំពង់ស្ពឺហ្នឹង ។

ប៊ុនថន : បាទ!អញ្ចឹងពូ តាប៉ាវហ្នឹងគាត់នៅខាងតំបន់៣២នេះរហូត?

ខន : បាទ!គាត់នៅបញ្ចឹងនេះមែន ប៉ុនគាត់នៅតាមទីរហូត ហើយបង កន ហ្នឹងក៏នៅតាមទីរហូតដែល ទល់តែ៧៩ហ្នឹង ។

ប៊ុនថន : បាទ!ប៉ុនពូថាត្រៀមឡើងម៉ោភាគអីដែលនោះ?

ខន : បង ប៉ាវហ្នឹង?

ប៊ុនថន : បាទ!?

ខន : គាត់ភាគ ប៉ុនភាគហ្នឹងប្រចាំនៅកំពង់ស្ពឺ បញ្ចឹមហ្នឹងប៉ុនគាត់នៅក្នុងកំពង់ស្ពឺហ្នឹងដដែលអត់ទៅនៅណាទេ អត់នៅភ្នំពេញនៅអីណាទេ គាត់នៅក្រុងកំពង់ស្ពឺហ្នឹង ប៉ុនគាត់ឡើងជាមួយ តាស៊ីវ ហើយតាស៊ីវបញ្ចឹមគាត់២នាក់ហ្នឹងហើយ មានតាស៊ីវ មានតាប៉ាវហ្នឹងហើយ ។

ប៊ុនថន : បាទ!តាស៊ីវ គាត់នៅរហូតគាត់នៅហ្នឹងរហូត គាត់នៅភូមិភាគរហូតឬគាត់មានដូរ?

ខន : ពីឆ្នាំប៉ុន្មានទេ ពីឆ្នាំ៧០ប៉ុន្មានទេ ៧៥-៧៦-៧៧ហើយឃើញគេដកគាត់យកទៅបាត់ ទៅគាត់ក្បត់យ៉ាងម៉េច ខ្ញុំអត់ដឹងដែរ គេថាតាស៊ីវ ហ្នឹងក្បត់ ។

ប៊ុនថន : គេដកគាត់ចេញពូ?

ខន : ដកចេញ មិនដឹងគេយកទៅណា ខ្ញុំអត់ដឹង ដកទៅបាត់តាប៉ាវ គាត់ជាប្រធាន ជាមួយតាប៉ាវហ្នឹង ។

ប៊ុនថន : បាទ!តាប៉ាវ ហ្នឹងឡើងជំនួសវិញ?

ខន : តាប៉ាវហ្នឹងចាស់ហើយ ចាស់ជាងគេ តាប៉ាវហ្នឹងគាត់នៅយូរហួត តាស៊ីវនោះគេដក បាត់តាស៊ីវ ហ្នឹងប្រធានៗលើតា ប៉ាវ ។

ប៊ុនថន : បាទ!

ខន : បើនិយាយពីភូមិភាគហ្នឹង ដល់ដកទៅខ្ញុំអត់សូវដឹងទេ មិនដឹងគេដកយកទៅណាទេ ព្រោះខ្ញុំនៅទ័ពហ្នឹងនៅតែព្រៃភ្នំហ្នឹង ។

ប៊ុនថន : កាលហ្នឹងដូចពូប៉ាវគាត់គណៈភូមិភាគ ហើយខាក្រោម?

ខន : បាទ!តាស៊ីវ តាប៉ាវ ក្រៅពីហ្នឹងម៉ោយើងក្រោមៗពីណាខ្លះទេ កងពលធំវាមាន តាស៊ីវ ។

ប៊ុនថន : តាស៊ីវ?

ខន : បាទ!តាស៊ីវហ្នឹងគ្រប់គ្រងកងពល ប៉ុនថាផ្នែកហ្នឹងបែបនៅជាមួយបញ្ចឹមហ្នឹង ។

ប៊ុនថន : ហើយពីណាទៀតពូ?

ខន : អត់ស្គាល់ទៀតផង ។

ប៊ុនថន : ចុះពេលដក ជូរ ចេត ហៅស៊ីវ ហ្នឹងអ្នកណាគេអ្នកដក ដូចថាមានដកតំបន់មានដកអីចេញ?

ខន : តំបន់ក្រោយម៉ោដក បងធឹមៗបញ្ជាការខ្ញុំ គាត់ធ្លាប់ដឹកនាំមេបញ្ជាខ្ញុំ គាត់វ៉ៃពីដើមល្អណាស់ ហើយគាត់នយោបាយក៏ល្អអប់រំក៏ល្អ ។

ប៊ុនថន : បាទ!មានដឹងថាដកទៅណាទេ?

ខន : អត់ដឹង ខ្ញុំអត់ដឹង ។

ប៊ុនថន : បាទ!

ខន : ដកបង ធឹម គឺចូលបង ឡេកវិញ បងឡេកហ្នឹងគេម៉ោគ្រប់គ្រង ពីដើមដកបានប៉ុន្មានខែមានខ្ញុយ មានខ្ញុំ មានអូន ទទួលរបស់យោធាហ្នឹង ដល់យើងនៅបានប៉ុន្មានខែទៀតបានគេថែមបង ឡេកហ្នឹងម៉ោថែមបង ឡេក ម៉ោជាប្រធានវិញ ។

ប៊ុនថន : ឡេក ហ្នឹងគាត់នៅខាងណាដែរពីមុន?

ខន : ពីមុនទៅខាងកងពលទី១ ។

ប៊ុនថន : កងពលទី១?

ខន :	កន៍ពលទី១ នៅខាងភូមិភាគបញ្ចឹម ។

ប៊ុនថន :	នៅជាមួយស្មឿង នៅជាមួយអីដែរ?

ខន :	បាទ!នៅជាមួយតា ស្មឿងអីហ្នឹង ។

ប៊ុនថន :	ហើយដកពីណាខ្លះទៀតពូ ក្រៅពីហ្នឹង?

ខន :	តាមខ្ញុំដឹងដកយោធាដែលដឹង ដក១បង់ធឹម តែមួយដកខ្ញុំអត់ដឹងមិនគាត់ទៅណា គេថាក្បត់ម៉េចអីម៉េច គាត់ដឹកនាំពីដើមគាត់អប់រំល្អណាស់ វប្បធម៌គាត់ក៏ខ្ពស់ដកគាត់បាត់ទៅនិយាយពីខាងអប់រំចិត្តសាស្ត្រវែអីៗហ្នឹងល្អណាស់ អប់រំសីលធម៌ សាមគ្គីជាមួយយុទ្ធជន យុវនារីឲ្យបានល្អ គាត់អត់មានដែលអប់រំឲ្យយើងមេទ័ពម្នាក់ៗហ្នឹង ហៅថាវាអំពើឃោឃៅទៅលើបងប្អូនយុទ្ធជនអី ប៉ុន្តែ ដល់ក្រោយម៉ោងដល់៧៥រំដោះជិតដល់ផ្ទះហើយបាន១ឆ្នាំ២ហើយបានដកស៊ីវ ដកស៊ីវហើយដកគាត់ឡើងទៀតទៅ ។

ប៊ុនថន :	បាទ!

ខន :	បាទ!បាត់គាត់ទៀតទៅក៏នៅតែខ្ញុំ នៅអួន នៅខ្ញុំទទួលបន្ទុកហ្នឹង តែវរៈហ្នឹង ពេលប្រជុំអីទៅធ្វើការហៅគាត់យកទៅ ទៅប្រជុំតំបន់អីឧទាហរណ៍ទៅប្រជុំតំបន់អីខាងឃុំខាងស្រុក ទាំងស្រុកអីទាំងអស់ទៅ យោធាហ្នឹងតំបន់ហ្នឹងយើងហៅប្រធានៗអ្នកទៅប្រជុំទៅរៀនសូត្រទៅប្រជុំគេដែល ។

ប៊ុនថន :	បាទ!អញ្ចឹងដកតាស៊ីហើយ តាប៉ាវ គាត់ឡើងជំនួស?

ខន :	បាទៗ!

ប៊ុនថន :	ចុះខាងតំបន់គាត់នៅគ្រប់គ្រងដែល តំបន់៣២ ក៏ដូរអ្នកថ្មីម៉ោ?

ខន :	អត់ទេ!តំបន់៣២ហ្នឹងពីមុននៅបង កន ទទួលបង កន ទទួល បង កន បងប្អូន សុន សេន ។

ប៊ុនថន :	អ្ហូ!នី កន ហ្នឹង?

ខន :	អ្ហូ! នី កន ហ្នឹង បង កនហ្នឹងឥឡូវនៅខាងណាទេ នៅម៉ាឡៃមិនដឹង ។

ប៊ុនថន :	បាទ!នៅម៉ាឡៃ ។

ខន :	បាទ!តែបងហ្នឹងក៏ល្អ អប់រំ គាត់ដើរតែជាមួយបង ធឹម ហ្នឹង គាត់មិត្តភក្រ័ជាមួយបងធឹម ហ្នឹងសុទ្ធតែអ្នកវប្បធម៌ខ្ពស់និយាយពីអប់រំគេរៀនសូត្រល្អម៉ង មិនសសើរទេ តែគាត់មិនដែលស្តីបន្ទោស ប៉ុន្តែមិនដែលអីម៉ោខាងយោធា ។

ប៊ុនថន :	បាទ!

ខន : នេះខ្ញុំមានដឹងតែប៉ុណ្ណឹង អញ្ចឹងសន្មេបហ្នឹងម៉ោ ក្រោយពីហ្នឹងម៉ោខ្ញុំ៧៩ហើយអូន ពេលដែលយួនចូលស្រុកម៉ោ ចាប់វ៉ៃគ្នា៧៨ហើយ ឆ្នាំ៧៨ចាប់ផ្ដើមផ្ទុះអាវុតខាងកើត ហើយសភាពការណ៍ អញ្ចឹងគេឲ្យត្រៀមៗការប្រយុទ្ធជាមួយយួន វៀតណាមហ្នឹង ។

ប៊ុនថន : បាទ!

ខន : នៅខាងបាស់បោល កម្លាំងបាស់បោល វាចេះតែមានសភាពការណ៍ចាប់មេៗ ចេះតែ នាំគ្នាភ័យហើយ ខ្លះថាខាងសីលធម៌ ខ្លះថាខាងក្បត់នេះ ឯខ្ញុំៗមិនប៉ះពាល់អីខ្ញុំ ហើយ ប្រជាជនក៏ខ្ញុំមិនដែលទៅធ្វើអី គ្រាន់តែអាណិតម៉ែឪ ឃើញចាស់ៗហើយគាត់ធ្វើគាត់ អីហ្នឹងឯង អត់ហានយកគាត់នៅជាមួយទេអូន ។

ប៊ុនថន : បាទ!

ខន : បាទ!ទុកគាត់ឲ្យនៅភូមិ ឃុំនោះម៉ងជាមួយគេទៅ ឯខ្ញុំវាមានទីតាំងគីរីរម្យ ភ្នំប្រាល ហ្នឹងម៉ាកងខ្ញុំហ្នឹងវាម៉ាសិទ្ធខ្ញុំហ្នឹងអត់មានអីទេ បងប្អូនធ្វើអីធ្វើទៅដាំដុះអី ផលិតតែទៅ នាំគ្នាហូបចុក ។

ប៊ុនថន : ដាំ ចុះអត់មានយកទៅផ្គត់ផ្គង់នៅអង្គភាពនៅលើទៀត?

ខន : អត់ទេ!ស្រូវអង្ករអត់យកទៅណាទេ ប៉ុនបើតែ ជិតហើយយកទៅឲ្យតំបន់ ផលិតបាន នារី៩០នាក់ហ្នឹងផលិតតែក្នុងមួយអាទិត្យៗបាន៥០០កញ្ចប់ ៤០០កញ្ចប់អញ្ចឹងទៅ ពីរអាទិត្យអីខ្ញុំដឹកយកទៅខាងតំបន់ភូមិភាគ ។

ប៊ុនថន : នៅណា នៅកំពង់ស្ពឺ?

ខន : នៅកំពង់ស្ពឺ ហើយអត់មានលុយមានកាក់អីទេ កាលហ្នឹងម៉ោគ្មានចាយអីទេដឹកយកទៅ ឲ្យគេទៅ ម៉ោវិញទៅ ។

ប៊ុនថន : ខាងពូហ្នឹងគ្រប់គ្រងនារី ៩០នាក់ហើយយុវជន?

ខន : យុវជនហ្នឹង៣វរៈសេនាធំ វាចូល៦-៧រយនាក់ដែរ ។

ប៊ុនថន : អ្ហូ!

ខន : បាទ!ខ្ញុំវរៈសេនាតូច ។

ប៊ុនថន : វរៈសេនាតូច?

ខន : បាទ!បើនិយាយវរៈធំវាជមួយគ្នា ប៉ុនចែកទៅគ្រប់គ្រងវរៈសេនាតូច ក្នុងវរៈសេនាធំ វា៣ហើយ បើនៅទន្លេនៅកំពង់ស្ពឺនេះគេគ្រប់គ្រងមន្ទីរអីហ្នឹង ហើយចុះទៅតាម ដូច ថាខ្ញុំស៊ីងប្រាលម៉ាកងវរៈតូច ហើយខាងត្រពាំងជួរអមលាំងនេះទៅម៉ាកងវរៈម៉ោ

ហើយនៅកំពង់ស្ពឺនោះម៉ាកងវរៈទៅ អញ្ចឹងខ្ញុំក្នុងសមាជិក គេហៅថាគណៈកម្មាធិការជាមួយវរៈសេនាធំមែនតែខ្ញុំជាស្នងការតូច ខ្ញុំមើលការខុសត្រូវច្រើន។

ប៊ុនថន : អញ្ចឹងបូកទៅជិត១០០០នាក់ដែរ?

ខន : បាទ!ជិត១០០០នាក់។

ប៊ុនថន : បាទ!ចុះខាងអមលាំងនេះខាងពីណាកាន់?

ខន : អមលាំងនេះ អួន។

ប៊ុនថន : ឈ្មោះអីអួន?

ខន : ភ្លេចបាត់ហើយ។

ប៊ុនថន : ចុះអួន ក្រោយម៉ោគាត់ដកទៅណាទៀត?

ខន : អួន ក្រោយម៉ោគាត់ស្លាប់ទេ ម៉េចទៀតបែកគ្នាទៅ៧៩នេះ។

ប៊ុនថន : ចុះឡេក?

ខន : ឡេក ហ្នឹងនៅខាងគ្រប់គ្រងវិញនៅខាងវរៈសេនាធំ ។

ប៊ុនថន : គ្រប់គ្រងភូមិភាគ?

ខន : អត់ទេ!គ្រប់គ្រងតំបន់ ឡេក ហ្នឹង៧៩ម៉ោរហូតក៏ម៉ោនៅនេះដែរ។

ប៊ុនថន : អ្ហូ!នៅណាវិញ?

ខន : បាទ!គាត់នៅខាងផ្ទះមួយនោះ។

ប៊ុនថន : ផ្ទះមួយ?

ខន : បាទ!

ប៊ុនថន : នៅមុំណាពូ?

ខន : នៅមុំផ្ទះមួយ នៅមុំជិតជ្រុំ។

ប៊ុនថន : ជិតជ្រុំ?

ខន : បាទ!ជិតជ្រុំ។

ប៊ុនថន : ឈ្មោះអីឡេក ពូ?

ខន : មិនដឹងឈ្មោះអីឡេក ទេ។

ប៊ុនថន : អញ្ចឹងគាត់នៅខាងជិតជ្រុំ?

ខន : បាទ!គាត់ប្រធានៗគ្រប់គ្រងក្រោយពីដកបង ធឹម ដកខ្ទុយ ដកអីម៉ោគាត់ទទួលម៉ោរហូត។

ប៊ុនថន : បាទ!ចុះពូផលនោះគាត់ខាងអីដែរ គាត់ដូចខាងបញ្ចើមដែរបពូ?

ខន : បងផល ឆក?

ប៊ុនថន : ផលនៅខាងស្រុក?

ខន : បងផល ស្រុកហ្នឹងគាត់នៅខាងភូមិភាគ កងពលទី១ ។

ប៊ុនថន : កងពលទី១?

ខន : បាទ!កងពលទី១ហើយ គាត់ក្រោយម៉ោគេដកទៅខាងស្រុកនោះ ខាងកោះកុងនោះ ។

ប៊ុនថន : ខាងស្រុក ឬខាងតំបន់ពូ?

ខន : អ្ហូ!តំបន់ៗ ។

ប៊ុនថន : បាទ!តំបន់កោះកុងតំបន់ ៣០?

ខន : ៣៧ ។

ប៊ុនថន : បាទៗ!អញ្ចឹងបង ផល គាតនៅនេះដែរ?

ខន : បាទ!ឥឡូវគាត់នៅនេះ ។

ប៊ុនថន : នៅជិតនេះដែរ?

ខន : ជិតដែរ ជិតផ្ទះខ្ញុំ តែគាត់នៅស្រុកម៉ង កាលពីមុននៅក្នុងកងពលមិនដឹងគាត់ទទួលអី គាត់កងពលទី១ខ្ញុំអត់សូវស្គាល់ទេ ។

ប៊ុនថន : អ្ហូ!អញ្ចឹងនៅខាងបញ្ចើមជាមួយពូដែរ?

ខន : បាទ!បញ្ចើមជាមួយគ្នាហ្នឹង ប៉ុនគ្រាន់កងពលផ្សេងអញ្ចឹង គាត់គេចល័តនេះនុ៎ះ ខ្ញុំអត់សូវដែល បងពន្ធកអីចៅស្រុកឥឡូវនេះក៏នៅកងពលជាមួយគ្នា ហើយបង សេក ឆន នេះប្រធានឃុំនេះក៏គាត់នៅខាងកងពលទី១ដែរ ។

ប៊ុនថន : បាទៗ!

ខន : ឯខ្ញុំៗអត់ទេ រឿងកងពលខ្ញុំអត់ដឹងគេទេ ដឹងតំបន់ ។

ប៊ុនថន : ចុះមានដកពូទៅវៃទេពូ?

ខន : បាទ?

ប៊ុនថន : មានដកពូទៅវៃ?

ខន : ខ្ញុំដឹក្រោយសភាពការណ៍ គេក្រៅគេ ខ្ញុំអត់ទេ ខ្ញុំអត់ដើង ដល់៧៩ហ្នឹងខ្ញុំជិះម៉ូតូម៉ោ ។

**ចប់**